ការសម្ភាសរបស់អ្នកមីង ពុធ ខន

ក៖ អ្នកសម្ភាសឈ្មោះ ញ៉ែម សុគន្ធា ខ៖ អ្នកត្រូវបានគេសម្ភាសឈ្មោះ ពុធ ខន

ជីវប្រវត្តិសង្ខេបរបស់អ្នកមីង ពុធ ខន

បងស្រីពុធ ខន គឺត្រូវបានកើតមកនៅក្នុងត្រកូលអ្នកក្រីក្រ ហើយឪពុកបានស្លាប់ចោលហើយ ហើយម្តាយក៏មានស្វាមីមួយទៀត ហើយគាត់ពេលរស់នៅជាមួយម្តាយគឺគាត់ពុំសូវមានម្ហូបអាហារគ្រប់គ្រាន់ទេ ហើយគាត់ថាគាត់ញុំតែផ្លែល្វា ដោយសារម្តាយគាត់ទៅតាមប្តី ហើយគ្មានអ្នកមើលថែទាំគាត់ហើយដោយអានិតក្តួយមីងរបស់គាត់បានយកគាត់អោយបាយញុំ។ពេលគាត់ធំឡើងគាត់បានដើររស់នៅជាមួយគេ ហើយចាញ់បោកគេ គេប្រើដោយគ្មានអោយប្រាក់ឈ្នួលហើយគេថា គាត់ត្រូវគេយកមកលក់ឱ្យគេ១ដីមាស។ ហើយដោយសារសេចក្តីអាណិតម្តាយក្មេករបស់គាត់បានយកគាត់ចេញពីគេហើយជួយ។ ហើយមិនបានយូរប៉ុន្មាន គាត់ក៏បានរៀបការហើយមានកូន២នាក់។ គាត់បានកើតទាន់សង្គ្រាមប៉ុល ពត ហើយ ការ ហូប ចុកគាត់ ថាមានការលំបាក។ សព្វថ្ងៃគឺគាត់មានជីវភាពពុំសូវស្រួលទេ ដោយសារគាត់ជាអ្នករ៉ាប់រងនៅ ក្នុងគ្រួសារតែម្នាក់ឯង ដោយសារស្វាមីគាត់ពិការហើយ ធ្វើការធ្ងន់មិនបាន ដូច្នេះគាត់ត្រូវធ្វើការដោយម្នាក់ឯង។

ក៖ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់បងស្រីដែលឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់បង នាងខ្ញុំឈ្មោះ ញ៉ែម សុគន្ធា ជាអ្នកសម្ភាសនៅក្នុងថ្ងៃនេះ ហើយថ្ងៃនេះថ្ងៃដែលពួកយើងសម្ភាសគឺនៅក្នុងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។ ហើយការសម្ភាសនេះគឺត្រូវបានប្រព្រឹត្តិនៅក្នុងភូមិព្រែករាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ហើយអើចឹងបងស្រីខ្ញុំប្រាប់ឈ្មោះពេញរបស់បង បងឈ្មោះអីគេដែរ?

ខ៖ ឈ្មោះ ពុធ ខន។

ក៖ ចាស! ហ្នឹងហើយ ចឹងបងតើបងធ្លាប់មានគេហៅឈ្មោះគេហៅខាងក្រៅអត់?

ខ៖ មាន!

ក៖ គេហៅអីគេវិញ?

ខ៖ ឈ្មោះបងម៉ៅ។

ក៖ បងម៉ៅ ចាសហ្នឹងហើយ។ ចឹងមានឈ្មោះអីក្រៅពីម៉ៅហ្នឹងទៀតអត់?

ខ៖ អត់មានទេ។

ក៖ តែមួយហ្នឹងទេហ៎?

ខ៖ ចាស! អត់ទេ អត់មានទេ។

ក៖ អត់ទេហ៎! មានតែប៉ុណ្ណឹង អត់អី! ចឹងបងស្រី តើបងស្រីកើតឆ្នាំខ្មែរបងកើតឆ្នាំអីគេដែរ?

ខ៖ ហ៊ីអត់ដឹងផងៗ

ក៖ អត់ចាំសត្វអីទេហេ?

ខ៖ អត់ដឹងផង អត់ចាំ។

(ស្វាមីរបស់បងស្រី) ៖ ឆ្នាំជូត ដំណាលដូច ដំណាលដូចប្អូនខ្ចីដែរឆ្នាំជូត។

កៈ ចឹងប្តីថាឆ្នាំជូត។ ចាស! ហើយចឹងបងស្រី បងស្រីមានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងទេ?

ខៈ អត់ចាំផងៗ

កៈ ប៉ុន្តែបងស្រីមាននៅក្នុងសំបុត្រកំណើត។

ខៈ ចាំ!

កៈ ចឹងខ្ញុំជួយអានហើយណា។ ចឹងបងស្រីឈ្មោះ ពុធ ខន កើតនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧១ ហ៊ឺកើតនៅក្នុងជំនាន់ លន់ នល់?

ខៈ ចាស!

កៈ ហ្នឹងហើយចឹងនៅក្នុងភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា ហើយមានម្តាយឪពុកឈ្មោះ បងស្រីប្រាប់ឈ្មោះឪពុកម៉ងទៅហ៊ឺ? ចាំគាត់ទេ?

ខៈ ចាំឈ្មោះ ភឿន។

កៈ ចាំស ភឿន!

ខៈ ភឿន។

កៈ ម្តាយទេអី?

ខៈ ម្តាយអី ឪពុក។

កៈ តែនៅក្នុងសំបុត្រកំណើតដាក់នៅនេះដាក់ម្តាយឈ្មោះ ភឿន។

ខៈ ដាក់ឧុសទេហ៊ឺ? ម្តាយឈ្មោះ ហ៊ឹម។

កៈ ហ្ន៎! ម្តាយឈ្មោះ ហ៊ឹម ឪពុកឈ្មោះភឿន។

ខៈ ចាស!

កៈ ចឹងគេដាក់ខាងនេះបញ្ហាស់គ្នា?

(ស្វាមីរបស់បងស្រី)៖ បញ្ហាស់!

កៈ ចឹងម្តាយឈ្មោះ ពុធ ហ៊ឹម ឪពុកឈ្មោះជាភឿនវិញ?

ខៈ ឪ ឈ្មោះ ភឿន។

កៈ ចាស! ហ្នឹងហើយប៉ុន្តែត្រកូលគាត់ជាភឿន?

ខៈ ចាស!

កៈ ហ្នឹងហើយ ហើយម្តាយឈ្មោះ ពុធ ហ៊ឹម?

ខៈ ចាស!

កៈ ចឹងសម្រាប់ឪពុកអ្នកមីងឈ្មោះជា ភឿន គឺគាត់កើតនៅក្នុងឆ្នាំ១៩៤០ នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជា ហើយម្តាយឈ្មោះ ពុធ ហ៊ឹម

កើតនៅក្នុងឆ្នាំ១៩៣៥ ពុធ ហ៊ីម នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកព្រៃវែង ខេត្តព្រៃវែង ប្រទេសកម្ពុជាដែរ។ ចឹងបង បងចាំថាម្តាយរបស់បងគាត់កើតឆ្នាំខ្មែរគាត់កើតឆ្នាំអីគេទេបង?

ខ៖ អត់ស្គាល់មិនគាត់កើតឆ្នាំអីផងៗ

ក៖ ចុះឪពុកវិញ?

ខ៖ ឪពុកអត់ដឹងដែរ បើខ្ញុំទម្ងន់បានៗខែហើយគាត់ស្លាប់ទៅ ខ្ញុំកើតអត់ទាន់ឪខ្ញុំផងហ្នឹងៗ

ក៖ ហើយថីមូលហេតុអីបានគាត់ស្លាប់បង?

ខ៖ អត់ដឹងដែរ។

ក៖ ម៉ែអត់ប្រាប់ទេហ៎?

ខ៖ គាត់អត់បានប្រាប់យើងផង ជំនាន់ហ្នឹងៗ

ក៖ ហ្ន៎ស្លាប់ពេលជំនាន់ប៉ុល ពតទេហ៎។ ហ៊ី! លន់ នល់តើ បើបងនៅក្នុងពោះ៧ខែ។

ខ៖ ខ្ញុំនៅក្នុងពោះ៧ ខែឪពុកញ៉ាំមស្លាប់ចោល។

ក៖ ហ្នឹងហើយនៅក្នុងលន់ នល់ទេ។

ខ៖ មិនទាន់គាត់ផងហ្នឹងៗ

ក៖ ហើយចុះសម្រាប់ម្តាយរបស់បងមានដូចជាអីគេមានប្រាប់ខ្លះៗអំពីឪពុកអត់?

ខ៖ អត់មានដែរ អត់បានប្រាប់កូនផងៗ

ក៖ ហ្នឹងហើយ។

ខ៖ គាត់អត់ដែលបានប្រាប់ផងៗ

ក៖ ចុះម្តាយរបស់បងគាត់ស្លាប់ឬមួយក៏រស់?

ខ៖ ម្តាយខ្ញុំស្លាប់យូរហើយ។

ក៖ តាំងពីណាមកវិញ?

ខ៖ តាំងពីបែកអាពតមក បែកមកគាត់ស្លាប់ម៉ងៗ

ក៖ ចា៎!

ខ៖ គាត់ទាស់ គាត់បានប្តីក្រោយហ្នឹង ប្តីមេអាពតហ្នឹងដល់តែបានកូនប្រហែលមួយខែគាត់ទូលអង្គរ កូនក្រោយហ៎ា។ ប្តីក្រោយបានកូនមួយ។

ក៖ ចា៎ស!

ខ៖ ដល់ចឹងគាត់ទូលអង្គរគាត់ទាស់ទៅឈឺរ៉ាំរ៉ៃៗទៅគាត់ក៏ស្លាប់ទៅ។

ក៖ ចឹងដោយសារទាស់ហ៎ចឹង?

ខ៖ ចា៎!

ក៖ ហើយចឹងដល់ឬនមីងអ្នកណាគេមើលទៅចឹង?

ខ៖ នៅជាមួយអ៊ុំខ្ញុំ។

ក៖ ចឹងហើយចុះប្អូនហ្នឹងនៅឯណាឥឡូវ?

ខ៖ នៅភ្នំពេញហ្ន៎ ឥឡូវប្អូនមានប្រពន្ធមានអីហើយហ្នឹង។

ក៖ ហ្ន៎!

ខ៖ មានកូន២ហើយឥឡូវ។

ក៖ ចំាស! ចឹងសម្រាប់ពោះតែមួយបងមានបងប្អូនប៉ុន្មាននាក់វិញ?

ខ៖ ខ្ញុំមានតែ២នាក់ហ្នឹង។ មានបងប្អូនតែ២នាក់គត់។

ក៖ ចំាស!

ខ៖ ខ្ញុំបងវា។

ក៖ តែគ្រាន់តែឪពុកផ្សេងគ្នា?

ខ៖ ចំាសឪពុកផ្សេងគ្នា។

ក៖ ចុះឪពុកចុងទៅណាវិញទៅ?

ខ៖ គាត់ស្លាប់ដែរ។

ក៖ ស្លាប់ដែរហៅ?

ខ៖ ចំាស!

ក៖ គាត់ស្លាប់មូលហេតុអីទៅ?

ខ៖ គាត់ស្លាប់ឈឺ។

ក៖ ហ្ន៎តែដល់ពេលបងធំមករស់នៅជាមួយប្អូនហ្នឹងដែរអី?

ខ៖ បាននៅតែខ្ញុំបែកប្អូនខ្ញុំតាំងពីនេះហ្ន៎! តាំងពីខ្ញុំអាយុ៦ ឬ ៧ឆ្នាំ មើល ១៥ឆ្នាំ។

ក៖ ១៥ឆ្នាំបែកពីប្អូនមក?

ខ៖ ចំាស! បែកពីប្អូនខ្ញុំដើរមកនៅជាមួយគេរហូត មកនៅអ្នកលឿងនេះបានអាយុខ្ញុំ ១៧ ឬ ១៨ បានខ្ញុំចេញមកនៅទីនេះ មកនៅជាមួយបងជារិននេះ។

ក៖ នៅព្រៃកហូរ?

ខ៖ ចំាស! នៅព្រៃកហូរ។

ក៖ ជួយលក់ចាប់ហ្ជាយគាត់ចឹងទៅ?

ខ៖ ចំាស! ហ្នឹងហើយ ជួយលក់ កាលហ្នឹងសួរគេថា យើងសុំលុយ គេបើកទិញខោអាវចឹងមកបងហ៎ា ដល់ទិញចឹងគេថា បើកលុយអី គេយកដៃងមកលក់ឱ្យអញមួយជីដល់ចឹង។

ក៖ មីងជារិននិយាយចឹង?

ខ៖ ចំាស! ហើយដល់ចឹងខ្ញុំប្រាប់ម៉ែក្មេកខ្ញុំចឹងថា អ៊ុំឯងមើលដល់ខ្ញុំសុំបើកលុយទិញខោអាវ គាត់ថាហ៊ីដៃងទារបើកលុយស្អីគេយកដៃងមកលក់ឱ្យអញមួយជីចឹងទៅណា ហើយចឹងក៏

ម៉ោង៥ ម៉ោង៥ខ្ញុំចេញ ចេញទៅ ចេញពីបងជារិនហ្នឹង ហើយចេញពីគាត់ហ្នឹងមកនៅជាមួយគាត់ហ្នឹងបណ្តោយ ដើរនៅហ្នឹងភ្នំពេញ ដើរនៅតែអីគ្រប់តែកន្លែងចឹងទៅ ទៅនៅគ្រប់កន្លែងទម្រាំបានប្តីខ្ញុំមកចឹងហិ។

ក៖ ហ្ន៎!

ខ៖ ដើរនៅគ្រប់កន្លែង។

ក៖ ចឹងបងដូចបងឯងនៅជាមួយមីងជារិនប៉ុន្មានឆ្នាំ?

ខ៖ ហៅនៅបានយូរដែរ។

ក៖ ដោយសារខ្ញុំប្រហែលមុខខ្ញុំនៅចាំមុខ។

ខ៖ ចាំស!

(ស្វាមីរបស់បងស្រី)៖ នៅប្រហែលអត់បានមួយទេ អត់បានទេ។

ខ៖ អត់មានមួយឆ្នាំផង គ្រាន់តែបានជិះហ្នឹង អត់បានមួយឆ្នាំទេ។

ក៖ ដោយសារខ្ញុំធ្លាប់លក់ដូរនៅមុខវត្តហ្នឹងដែរហ្ន៎។

ខ៖ ចាំស!

ក៖ ចឹងខ្ញុំចាំមុខមួយហ្នឹង។ ហ្នឹងហើយចឹងបងតើបងប្អូនប្រុសរបស់បងគាត់ឈ្មោះអីគេដែរ?

ខ៖ ប្អូនខ្ញុំហ៎?

ក៖ ចាំស!

ខ៖ ឈ្មោះ រឿន។

ក៖ ស្អីគេរឿន?

ខ៖ ហ៊ីមិនដឹងស្អីទេនេះ?

ក៖ អត់ចាំត្រកូលគាត់ទេហេ?

ខ៖ អត់ចាំទេ។

ក៖ ចាំស! បែកគ្នាតែនេះ មិនដែលបាននៅជាមួយប្អូនផង។

ក៖ ឥឡូវគាត់រស់នៅភ្នំពេញ?

ខ៖ ចាំស វាមកនៅស៊ីឈ្នួលនៅភ្នំពេញនេះ។

ក៖ ហ្ន៎! គាត់មានគ្រួសារហើយ?

ខ៖ មានហើយហើយ។

ក៖ គាត់រកស៊ីអីគេបង គាត់ស៊ីឈ្នួលធ្វើអីគេវិញ?

ខ៖ ដើរជាមួយអាចើមនេះ មិនដឹងខាងអី ខាងថតអីចឹងទៅណា។

ក៖ ដើរជាមួយអាចើម?

ខ៖ចាស! ប្អូនខ្ញុំដើរ អាចើមពួកម៉ាក់វា ពួកម៉ាក់គេហ្នឹងហ៎ា។ គេដើរមួយគ្នាហ្នឹង។

ក៖ អាចើមកំប្លែងហ្នឹងហេ?

ខ៖ ចាស!!

(ស្វាមីរបស់បងស្រី)៖ អាចើមតួកំប្លែងហ្នឹង។

ក៖ ដើរជួយថតជួយអីចឹងទៅ?

ខ៖ ដើរថតដើរអីចឹងទៅ។

ក៖ ហ៊ុចឹងបានលុយច្រើនដែរតើ អាចើមល្បីហ៎ាណា។

ខ៖ ល្បីតែគេតែវាអត់បានលុយ វាស៊ីឈ្នួលគេ។

ក៖ ចាស! ស៊ីឈ្នួលជាមួយអាចើមដើរថតអីចឹងទៅ។

ខ៖ ចាស វាបានប៉ុន្មានរឿងដែរ វាបានថតចូលទៅក្នុងទូរទស្សន៍ហ៎ា អាប្អូនខ្ញុំហ្នឹងហ៎ា។

ក៖ ហ្គ៎! ឈ្មោះអីគេវិញ?

ខ៖ ឈ្មោះរឿន មិនដឹងត្រកូលវាថាដាក់ឈ្មោះអីគេទេ ខ្ញុំមិនដឹងអីមិនដឹងទេ។

ក៖ អ្នកសិល្បៈដែរ។

ខ៖ ក្រែងលោវាដាក់ខុសគ្នា។

(ប្តីរបស់បងស្រី)៖ រឿនហ្នឹងគេហៅ មួយទៀតគេហៅក្រៅ ដល់ទៅក្រៅគេហៅអាពៅហ្នឹង។

ក៖ ចាស!

ខ៖ អាពៅប្រុសពៅហ្នឹង។

ក៖ ចាសចឹងបងមានបងប្អូនតែ២នាក់ហ្នឹងទេ?

ខ៖ ចាសមានតែ២នាក់ហ្នឹង។

ក៖ បងនៅពីក្មេងធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះជាមួយប្អូន ពេលចាំបានចឹងហ៎ា?

ខ៖ អត់ធ្លាប់មានអនុស្សាវរីយ៍អីគេផង។

ក៖ ធ្លាប់លេងអីគេខ្លះជាមួយគាត់?

ខ៖ អត់ដែលបានលេងអីជាមួយប្អូនផង។

ក៖ ហ្គ៎! រស់នៅធម្មតាចឹងទៅ?

ខ៖ ចាស!

ក៖ ធ្លាប់លេងបៃឡកបៃឡរអីជាមួយគ្នាអត់?

ខ៖ ហ៊ុ! អត់ដែលផង។

ក៖ លេងផ្សេងៗគ្នាចឹងទៅ?

ខ៖ ចំាស! មានដែលបានលេងអីជាមួយប្អូនទេ។ ព្រលឹមឡើងទៅមើលក្របី ទៅមើលអីចឹង ទៅកា លហ្នឹងយើងនៅស្រុកទេណា។ បងហ៎ា យើងនៅតូចយើងទៅមើលក្របីមើលអីចឹង ទៅ។

ក៖ ចំាស ហ្នឹងហើយ។

ខ៖ ក្លានបានមើលប្អូនអីទេ។

ក៖ មើលក្របីចឹងអោយមីងឱ្យអីចឹងទៅអី?

ខ៖ ចំាស! មើលអោយអ៊ុំ។

ក៖ ចំាស! តែគាត់ចេះចិញ្ចឹមបងអីចឹងមកដែរ អីចឹងទៅណា។

ខ៖ ចំាសគាត់រកចិញ្ចឹមយើងដែរ។

ក៖ ចំាស! ហើយបានបែកចេញពីគាត់មកស៊ីឈ្នួលអីចឹងមក?

ខ៖ បែកពីគាត់ចឹងមកនៅលិចអ្នកលឿងហ្នឹង។

ក៖ ហ្នឹងហើយ។

ខ៖ មកស៊ីឈ្នួលស្លូងស្រូវ ច្រូតស្រូវអីគេហើយដល់ម៉ែឪធម៌ខ្ញុំដូចថាហើយចូលសួរខ្ញុំចឹង ហ៎ា ហើយប្រកែកថាអត់យកអត់យកចឹងហើយគាត់ចេះតែឱ្យគេទៅដល់ចឹង ខឹងគាត់រត់ចេញពីគាត់ចឹងមក នៅជាមួយជារៀនហ្នឹង។

ក៖ ហ្ន៎! ចឹងដោយសារខឹងទេចឹង?

ខ៖ ចំាស! ចេញមកនៅជាមួយបងជារៀនខាងគាត់ថាហ៊ីអញឱ្យគេវាប្រកែកចឹងខ្ញុំប្រកែកខ្ញុំថាអត់យកហ៎ា
ហើយញ៉ែមចេញមកទៅជិះរម៉ក់មក។

ក៖ យីចិត្តធំទៀត។

ខ៖ ចុះបើប្រកែកហើយនៅតែបង្ខំឱ្យយក បើគេមិនចង់បានបង្ខំម៉េច។

ក៖ គាត់ឱ្យមានប្តីមានអីចឹងទៅហ៎?

ខ៖ ចំាស! គេចូលសួរឡើង៣ ឬ ៤នាក់ហ្ន៎។

ក៖ ពេលហ្នឹងអាយុប៉ុន្មានវិញ?

ខ៖ ១៨ហើយ។

ក៖ ចឹងបង បងចាំទេថាឪពុកម្តាយរបស់បងគាត់ធ្លាប់រកស៊ីអីពីមុនមកចាំអត់?

ខ៖ ហ៊ីកើតមកម្តាយបែករហូត មិនដែលជួបជុំម្តាយផង។

ក៖ ហ្នឹងហើយ។

ខ៖ យប់ឡើងម៉ោង១បានម្តាយមកយក លួចពីមីងខ្ញុំទៅហិ។ មីងខ្ញុំគាត់អានិតខ្ញុំចឹងហ៎ាគាត់លួចចឹងទៅឱ្យខ្ញុំស៊ីផ្លែល្វា ឡើងដើមល្វាហ៎ា ស្គាល់ដើមល្វាអត់?

ក៖ ស្គាល់ អារលួយក្តងហ្ន៎។

ខ៖ ដើមវា ចាស! ហើយម៉ោងមួយម៉ែខ្ញុំមកចឹង ហើយគាត់បាន បាយមួយដុំមាន់អីចឹងទៅហៅកូនឱ្យស៊ី ប៉ុន្តែខ្ញុំស៊ីផ្លែល្វាឡើងចង់ងាប់ហើយហ្នឹងចង់ងាប់ចង់រស់ហើយ។

ក៖ ហើយហូបជាមួយអីគេទៅ?

ខ៖ ផ្លែល្វាទទេម៉ង! ចុះកាលហ្នឹងខ្ញុំនៅតូច ប៉ុនៗក្មួយខ្ញុំហ្នឹង ប៉ុនកូនអាគ្រាហ្នឹង មីធាហ្គំ។

ក៖ ចេះតែដាក់ចូលមាត់ទៅ?

ខ៖ ចាស! ឡើងទៅ ជំនាន់ហ្នឹងបានអីស៊ី មានតែផ្លែហ្នឹងស៊ីបងអើយ ដល់ស៊ីចឹង មិងខ្ញុំគាត់ទៅលួចមកតើ លួចពីម៉ែខ្ញុំមកហ្នឹង។

ក៖ ចាស!

ខ៖ ដល់តែលួចចឹងមកតែល្ងាចឡើងគាត់ជិះរទេះ សេះមកជាមួយប្តីគាត់ចឹងហ៎ា។

ក៖ ចាស!

ខ៖ មកយកខ្ញុំទៅហើយខំយកក្មួយទៅដាក់ពួននៅហ្នឹង ដើមខ្ពុហ្គំ ហើយឡើងមកវិញឈ្លើងទាមឱ្យរញ៉ៃ។

ក៖ អើយ! ទាមបងហ្នឹង?

ខ៖ ទាមខ្ញុំហ្នឹងហ៎ា។

ក៖ ហើយអត់ ហើយម៉េចទៅអោយឈ្លើងទាមចឹង?

ខ៖ ហ៎ា! បើពួនម្តាយ ម្តាយទៅយក មិងអត់ឱ្យយកមកហ៎ា។

ក៖ នៅជាមួយម្តាយវាយ៉ាងម៉េច វាពិបាកហូបឬក៏ម៉េច?

ខ៖ គាត់យកទៅអត់ឱ្យមានយើងហូបអីផងឱ្យស៊ីតែផ្លែល្វាហ្នឹង។

ក៖ ម៉ែហ៎?

ខ៖ ចាសម៉ែខ្ញុំហ្នឹងហ៎ា។

ក៖ ហើយមីងអាណិតទៅយកមក?

ខ៖ ចាសហ្នឹងហ៎ា! ហើយមីងអាណិតទៅយកក្មួយមកវិញ។

ក៖ ហើយចុះម៉េចចឹងវិញអត់មើលថែកូនទេចឹង?

ខ៖ អើ បើគាត់ដើរតាមតែប្តីគាត់។

ក៖ ហ៊ីអត់ខ្វល់ពីកូន កូនស្រី។

ខ៖ ដើរ!

ក៖ យ៉ាងម៉ង!

ខ៖ គាត់ដើរតែតាមតែអីតាមប្តីគាត់អីចឹង ដល់យប់ចឹង ម៉ោង១ ម៉ោង២អីចឹងបានចូលផ្ទះ ហើយខ្ញុំនៅតែម្នាក់ឯងដេកនៅអាដើមល្វាហ្នឹង នៅដង្កៀបហ្នឹង អង្គុយហ្នឹងទៅ ដល់ចាំម្តាយយូរពេកដេកចឹងទៅ ហើយចុះជំនាន់ហ្នឹងដូចតែយើងនេះចឹង ខ្លាចចឹងចេះតែនេះទៅ ហើយផ្ទះគេ ស្ងាត់ឈឹង។

កៈ ហើយអត់សូវមានមនុស្សច្រើនទេបងនៅ?

ខៈ អត់សូវ ចាំអត់សូវមានមនុស្សទេ។

កៈ ហ៊ីចេះតែមានម៉ងហើយនៅព្រៃវែងរាងដាច់ស្រយាលដែរហ្នឹងហ៎ា?

ខៈ ហ៊ី! មានព្រៃហ្គំកាលហ្នឹង។

កៈ ចាំស!

ខៈ ហើយពេលយួនទម្លាក់មកអីរត់ពួនគុម្ពឬស្សី គុម្ពអីហ្គំ។

កៈ ពេលហ្នឹងជំនាន់ទម្លាក់គ្រាប់មែនទេ?

ខៈ ចាំស! ទម្លាក់គ្រាប់។

កៈ ហ្នឹងហើយ។

ខៈ កប៉ាល់ហោះហ្នឹងទម្លាក់គ្រាប់មកយើងមិនពួននឹងភ្លឺស្រែហ៎ា ក្រាបម៉ង។

កៈ ចាំស! ដោយសារបើម៉េចៗខ្មាត់មកត្រូវមកហ៎ាបានក្រាប?

ខៈ ចាំសត្រូវ! ហើយបើចឹងហើយបើថាយួនវាចូលមកយកវាជីកគេហៅអីគេ គេជីក។

កៈ ត្រង់សេ។

ខៈ ហ្នឹងហើយ! ហើយចូលហើយវាទៅបាត់ទៅបានយើងឡើងមកវិញមក ចូលទៅហ្ន៎ កាំភ្លើង ព្រុងរ៉ូហ៎ា ថ្ងៃមួយខ្លំភ័យចុះវាទាត់យើងដែរ តើបើយើងរត់ចូលក្តងនេះលឿនហ៎ា គ្រាន់តែ ឃើញវាណោះយើងរត់ចូលក្តងនោះព្រុច។

កៈ ចាំស! ដឹងអ្នកណាគេទម្លាក់គ្រាប់ទេពេលហ្នឹង? ដូចពេលហ្នឹងជំនាន់ លន់ នល់ ទាហានអាមេរិចទម្លាក់គ្រាប់ សម្លាប់ពួកយៀកកុងនោះពូហ៎?

(ប្តីរបស់អ្នកមីង)៖ ហ្នឹងហើយ។

ខៈ ហ្នឹងហើយដែលថាដេញពួកអាពតដេញកាប់អីចឹងទៅណា។

កៈ ចាំស!

ខៈ វានៅឯណោះដេញកាប់អាកាំបិតនោះឡើងសររលាម ហ្គំខ្លំរត់ចូលក្តងស្រូវហ្គំ។

(ប្តីរបស់អ្នកមីង)៖ ជំនាន់៧១ (១៩៧១ ១៩៧២) ទម្លាក់គ្រាប់តើ ឆ្លងកាត់ដែរតើ។

ខៈ គួរឱ្យខ្លាចណាស់ កាប់នោះកាប់ឡើង ដូចថាកាប់គ្នាទាំងរស់ទាំងអីទៀតហ្គំ។

កៈដាច់ករទៅ?

ខៈ ចាំស! ហ្គំ! ខ្លំខ្លាច ហើយចុះកាលហ្នឹងវាតូចដែរហ្គំ។ គេដេញមកបែកទឹកសំពោងខ្លំរត់ចូលក្តងស្រូវពួនវាហ៎ា។

កៈ ម្នាក់ឯង?

ខៈ ម្នាក់ឯងកាលហ្នឹងដើរ មាននេះឯណា ខ្លាចចង់ងាប់ហើយណា កាលជំនាន់អាពត។

(ប្តីរបស់អ្នកមីង)៖ ជំនាន់ហ្នឹងត្រង់សេក៏មានពស់ដែរហ៎ា ខ្លះពស់ចឹកងាប់ហ៎ា។

ក៖ ចំាស! ហើយចេះរស់បានដល់សម័យហ្នឹងដែរ?

ខ៖ ចំាស! ចេះរស់បានដល់ឥឡូវដែរ។

ក៖ថ្លៃហាណោះជីវិតបងណោះ?

ខ៖ ចំាស!

ក៖ ចឹងបងតើសព្វថ្ងៃបងមានអាយុប៉ុន្មានហើយ?

ខ៖ ទាល់តែសួរប្តីខ្លុំ។

ក៖ ប្តីប្រពន្ធអាយុប៉ុន្មានហើយពូ?

(ស្វាមីរបស់អ្នកមីង)៖ ៤០ជាង ៤៦។

ខ៖ ៤៦ ឬ ៤៧ហើយអី?

ក៖៤៧ហ្នឹងហើយហើយដោយសារពូហេងកើត១៩៦៦អ្នកមីងកើត១៩៧១ ចឹងបងប្អូនគ្នា២ឆ្នាំ មីង៤៩ ពូ៤៧ ហើយ។

ខ៖ ចំាស! គាត់បងខ្លុំ២ឆ្នាំ។

ក៖ ជិតពាក់កណ្តាលហ៊ាហើយតើមួយៗ ចឹងបងតើសម្រាប់ជីវិតរបស់បង បងធ្លាប់រកស៊ីអីគេខ្លះហើយ អាចរៀប រាប់ទាំងអស់ថាធ្លាប់រកស៊ីអីគេខ្លះ?

ខ៖ តាំងពីនេះមកហ៎?

ក៖ តាំងពីក្មេងរហូតដល់ប៉ុណ្ណឹង?

ខ៖ មិនដឹងរកស៊ីស្អីបើដើរនៅជាមួយគេរហូត។

ក៖ នៅជាមួយធ្វើអីគេខ្លះវិញ?

ខ៖ នៅជាមួយគេលក់ដូរចឹងទៅ ចេញពីបងជារិនទៅនៅផ្សារថ្មីជួយលក់ដូរគេចឹងទៅ ចោកខោអាវចោកអីចឹង ទៅណាមិនដឹងរកស៊ីអី។

(ស្វាមីរបស់បងស្រី)៖ ដើរស៊ីឈ្នួលតាមផ្ទះ។

ខ៖ ជូតផ្ទះ ព្រលឹមឡើងជូតផ្ទះឱ្យគេ ចោកខោអាវឱ្យគេហើយបានដាំបាយហូប ជួយធ្វើនំធ្វើអីឱ្យគេចឹងទៅ កាល ហ្នឹងនៅផ្សារថ្មី។

ក៖ ហ្ន៎!

ខ៖ ហើយបើនៅជាមួយបងជារិន ព្រឹលឹមឡើង ដឹងតែលក់ដូរចឹងទៅ។

ក៖ ជួយលក់ ជួយអីគាត់ចឹងទៅ?

ខ៖ ចំាស លាងចាន លាងឆ្នាំងចឹងទៅ។

ក៖ ហ្នឹងហើយ។

(ស្វាមីរបស់បងស្រី)៖ ចេញមកពីគេហើយធ្វើអីគេទៀត? ឈប់នៅជាមួយគេលក់បន្តែលក់អី។

ខ៖ នៅពេលបានប្តីខ្លុំមកបានលក់បន្តែ។

ក៖ នៅផ្សារណារិញ?

ខ៖ នេះនៅផ្សាររោងចក្រហិ។

(ប្តីរបស់បងស្រី)៖ មុនលក់ឥវ៉ាន់ចាប់ហ្ជីយនៅមុខផ្ទះដែរហ្នឹង។

ក៖ ចំាស! ម៉ែចបានឈប់អស់ចឹង?

ខ៖ វាយើងលក់វាមិនបានស៊ី។

ក៖ រវល់តែខាតហេំ?

ខ៖ ចំាសរវល់តែខាត។

ក៖ ចំាស!

ខ៖ លក់អត់បានហូប។

(ស្វាមីរបស់បងស្រី)៖ បានគេឱ្យខ្ញុំដើរចុងភៅបានដើររហូត។

ខ៖ បានដើរចុងភៅបានគ្រាន់នេះទប់ទល់បងហ៉ា។

ក៖ ចំាស! ហើយចុះបើសិនជាខែអត់មានការរិញម៉ែចទៅ?

ខ៖ អត់ការត្រូវបោកខោអាវ បោកខោអាវចឹងទៅ ត្រូវធ្វើស្មៅ ធ្វើស្មៅទៅ។

ក៖ ហ្ហ៉! តែមានជាប្រចាំរហូតហេំមុខរបរ?

ខ៖ ចំាស!

ក៖ ហ្នឹងហើយនៅតែមានដែរ ចឹងខំប្រឹងដើម្បី ឱ្យកូនបានទៅរៀន ដើម្បីពេលធំឡើងមានអនាគត។

ខ៖ ចំាស!

ក៖ ហើយចឹងទៅបានស្រួលបងហើយនឹងពូ។

ខ៖ ចំាស!

ក៖ ហ្នឹងហើយ។

ខ៖ តែបោកខោអាវនេះបានចឹងមកបាន១០,០០០ឬ ២០,០០០អីចឹងទៅបានអោយលុយកូនទៅរៀនទៅ។

ក៖ ចំាស! ជារៀងរាល់ថ្ងៃដែរមីង

ខ៖ ចំាស!

ក៖ ហ្នឹងហើយល្អមែនទែន។ ចឹងបងតើសម្រាប់ស្វាមីរបស់បងគាត់ឈ្មោះអីគេដែរ?មិញប្តីប្រាប់ហើយ ឥឡូវសួរ ប្រពន្ធម្តង។

ខ៖ ឈ្មោះ ជា លីហេង។

ក៖ ចំាស! ហ្នឹងហើយ ចឹងមិញពូហេងគាត់កើតនៅក្នុងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៩។ នៅភូមិភ្នំសពៅ ឃុំភ្នំសំពៅ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ប្រទេសកម្ពុជា ហ្នឹងហើយចឹងស្វាមីរបស់បង

ខ្ញុំអាននៅក្នុងសំបុត្រកំណើត ទេណ៎ា ខ្ញុំអត់ដឹងទេណោះ។ ចាស! ហ្នឹងហើយចឹងសូមប្រាប់ពីប្រវត្តិស្នេហា។

ខ៖ ហ្ន៎! អត់មានទេ។

ក៖ អូខេ ចឹងតើបងរៀបការនៅក្នុងឆ្នាំណា?

ខ៖ មិនដឹងឆ្នាំណា។

ក៖ ពូហេងចាំជាង ឆ្នាំការ?

ខ៖ អត់បានការសែនរៀប។

(ស្វាមីរបស់បងស្រី)៖ ៩៦ (១៩៩៦)។

ក៖ ចឹងរៀបហ្នឹងនៅក្នុងឆ្នាំ១៩៩៦?

ខ៖ ចាំស!

ក៖ ចាំស ហ្នឹងហើយ ចឹងការរៀបការហ្នឹងម៉េចដែរបង អើដូចជារៀបចំឡើងដោយអ្នកណាគេ ឬក៏ស្រឡាញ់ ដោយចិត្តឯងដែរ?

ខ៖ ស្រឡាញ់ចិត្តឯង។

ក៖ ស្រឡាញ់ចិត្តឯងហ៎?

ខ៖ ចាំស!

ក៖ ស្រឡាញ់ប្តីយូរនៅ? ពូហេងនៅហ្នឹងអត់ហ៊ាននិយាយហ៎? ម៉េចដែរ មើលប្រាប់ពីប្រវត្តិស្នេហាអីតិចមើល ប្រាប់បន្តិចមក?

ខ៖ អត់ចេះទេ!

ក៖ អូខេ! ឥឡូវជួបគ្នាដំបូងជាមួយពូនៅឯណា?

(ស្វាមីរបស់បងស្រី)៖ នៅហ្នឹង។

ខ៖ នៅហ្នឹងផ្ទះ។

ក៖ នៅផ្ទះហ្នឹងហ៎?

ខ៖ ចាំស!

ក៖ ដោយសារម៉េចបានមកដល់ផ្ទះពូដែរ?

ខ៖ ខ្ញុំនៅជាមួយបងជារិនហ្នឹង។

ក៖ ចាំស! ហើយដល់ពេលបន្ទាប់ម៉េចទៀតបានមកណោះវិញ?

ខ៖ ខ្ញុំចេញពីបងជារិនទៅនៅភ្នំពេញដល់តែនេះសុំគេមកលេងស្រុក ដល់ពេលចឹងមកផ្ទះហ្នឹងម៉ែខ្ញុំ គាត់ទៅសួរ ទៅអីចឹងទៅណា។

ក៖ ចាំស!

ខ៖ ទៅសួរខ្ញុំដល់ព្រៃវែងហ្នឹង។

កៈ ហ្ន៎! ដើម្បីឱ្យបានមកការមកអីចឹងមក?

ខៈ ចំាស! អត់បានការទេសែន។

កៈ សែនហ្នឹងហៅ។

ខៈ ចំាស! និយាយត្រង់អត់មានលាក់ទេ។

កៈ មានអីសែន ឬក៏ការអីឱ្យបានត្រឹមត្រូវ។

ខៈ ចំាស!

កៈ ចឹងបងសម្រាប់ភាសាវិញ តើបងចេះ អាន និង សរសេរភាសាខ្មែរបានច្បាស់អត់?

ខៈ អត់បានចេះផងៗ។

កៈដែលធ្លាប់រៀនទេ?

ខៈ អត់ដែលបានរៀនសោះ។

កៈ ចុះនៅតាំងពីក្មេងមកអ៊ុំអត់ដែលបានឱ្យទៅសាលាទេចឹង?

ខៈ អត់បានម្តងៗ ទៅខោរហែក ខ្ញុំស្លៀកខោប្រដីបជំនាន់ហ្នឹងនោះ។

កៈ មើលនិយាយតិចមើលម៉េចដែរ?

ខៈ ខ្ជិលនិយាយខ្មាសគេ។

កៈ មកនិយាយប្រាប់មក។

ខៈ ចាំមើលកាលហ្នឹងខ្ញុំនៅតូចដែរ ទៅទៅអ៊ុំខ្ញុំឱ្យខ្ញុំទៅរៀន ទៅចឹងស្លៀកខោរហែកចំកូនក្រូហៅឡើងរាប់ អក្សរហ្ន៎ ស្រះអ ស្រះអា ស្រះអិ ស្រះអីហ្នឹង។

កៈ ចំាស!

ខៈ មានគេថាហ្ន៎ ខោដែងរហែកៗខ្ញុំក៏អៀនខ្ញុំក៏លែងទៅរៀនរហូតទាល់តែឥឡូវហ្នឹង។

កៈ ដោយសារចឹង។ ហើយដល់ពេលនៅផ្ទះហ្នឹងអត់ព្រមមើលឱ្យហើយ?

ខៈ អត់បានមើលផងៗ ទោះតែមើលក៏អត់មានខោស្លៀកដែរ បើមានតែខោមួយបម្លាស់។

កៈ អ៊ុំគាត់អត់មានទិញខោអារអីឱ្យស្លៀកទេចុះ?

ខៈ ចំាស! ជំនាន់ហ្នឹងមានខោអារមកពីណា ខោអារមួយបន្ទាស់ចង់មួយរយបន្ទាស់ហើយហ្នឹង។

កៈ មិនដូចឥឡូវពាក់ហើយចោល។

ខៈ ឥលូវសម្បុរចង់ងាប់ កាលហ្នឹងខោបន្ទឹបពណ៌ខ្មៅយើងហ្នឹង។

កៈ ចំាស!

ខៈ បានអារថ្មីមួយហ្នឹង ដូចបានម៉ែបានឪចឹង។

កៈ ចំាស! ចឹងបើសិនជាភាសាខ្មែរតើបងធ្លាប់រៀនភាសាអីផ្សេងក្រៅពីភាសាខ្មែរអត់?

ខៈ អត់ទេ។

កៈចេះតែភាសាខ្មែរនិយាយមួយហ្នឹងទេហ៎?

ខៈ ចំា!!!អត់ចេះទេ។

កៈ ចឹងពេលទៅរៀនដំបូងហ្នឹងបងចាំថាទៅរៀននៅឯណាអត់?

ខៈ រៀននៅវត្តស្វាយជ្រំ ។

កៈ ស្វាយជ្រំនៅ!

ខៈ នៅស្រុកខ្ញុំហ្នឹង ព្រៃវែង។

កៈ នៅព្រៃវែងហ្នឹង?

ខៈ ចំាស!

កៈ គេហៅសាលាឈ្មោះអីគេវិញសាលាស្វាយជ្រំចឹងទៅ?

ខៈ ចំាសសាលាស្វាយជ្រំចឹងម៉ង។

កៈ ចំាសហ្នឹងហើយ។ ចឹងបងពេលបងនៅរៀនហ្នឹងបងមានអើមិត្តភក្តិអីស្និតស្នាលអីជាមួយគ្នាអត់?មានមិត្តភក្តិអីចឹងហ៎ា?

ខៈ អត់ផង!

កៈ ដូចតែឯងៗម៉ងហេ?

ខៈ អត់មានទេ!

កៈ ចឹងសម្រាប់នៅពេលពីក្មេងឬក៏មានធ្លាប់ធ្វើស្រែចម្ការអីទេមួយជីវិតហ្នឹងមកហ៎ា?

ខៈ ធ្លាប់!

កៈ ម៉េចដែរបង?

ខៈ ស្ទូងស្រូវដកចឹងទណ៎ា។

កៈ ចំាស!

ខៈ ពេលដែលនេះមកពីមើលក្របីចឹងវិញ ដក ដកហើ យយើងរែកកណ្តាប់ទៅស្រែព្រលឹមឡើងទៅញ្ជរដី ស្ទូង ចឹងទៅ។

កៈ ចំាស! ហ្នឹងហើយ ចឹងជួយ។ មួយហ្នឹងធ្វើឱ្យអ្នកណាគេវិញ? ស៊ីឈ្នួលគេឬមួយធ្វើឱ្យអ៊ុំមីង?

ខៈ ធ្វើឱ្យអ៊ុំខ្ញុំ ប៉ុនខ្ញុំនៅជាមួយអ៊ុំខ្ញុំហ៎ា។

កៈ ចំាស! ធ្លាប់ធ្វើស្ករត្នោតអីអត់?

ខៈ ហ៎ា! អត់ដែលធ្វើសោះ ទៅធ្វើអីស្មានតែឡើងដើមត្នោតរួច។

កៈ លោអ្នកណាគេឡើងចឹងបងឯងអ្នកកូរចឹងទៅណ៎ា។

ខៈ អត់ទេ បងអត់ទេ។

កៈ ចឹងធ្លាប់រេញកន្ទេល រេញកន្ត្រែកអីអត់?

ខ៖ កន្ទេលធ្លាប់ធ្វើ។

ក៖ ធ្វើម៉េចទៅ ប្រាប់ខ្ញុំចិត្តមើល?

ខ៖ ដំបូងអាហ្នឹងយើងធ្វើស្លឹករំចេកហ៊ាយើងកាត់ កាត់ហើយយើងយកមកជៀរយកបន្ដែហើយយើងមូលហើយសួតយើងយកមកកួតវាត្រង់ ត្រង់ហើយយើងឈូតវា។

ក៖ ចំាស! ឈូតហើយយើងធ្វើកន្ទេលទៅ។

ក៖ ចំាសហ្នឹងហើយ ហើយចឹងធ្លាប់ធ្វើមួយហ្នឹងទៅលក់ឬក៏ទុក?

ខ៖ ធ្វើលក់ លក់កាលហ្នឹងមិនដឹងបានប៉ុន្មានទេ ខ្ញុំភ្លេចយូរហើយ។

ក៖ ហើយដើរ ធ្វើហើយទូលលក់ទៀត?

ខ៖ អត់ទេខ្លះធ្វើហើយ មានគេអ្នកមកទិញតាមផ្ទះ។

ក៖ ចំាស!

ខ៖ ខ្ញុំធ្វើក្នុងមួយថ្ងៃបានកន្ទេល ២។

ក ៖ហូយ៎បានច្រើនដែរចឹង។

ខ៖ ចំាស អាអញ្ចេះចឹង៣ហត្ថកន្លះ។

ក៖ ចំាស!

ខ៖ ហើយអាបណ្ដោយនេះ៦។

ក៖ ឆ្ងាយធំ។

ខ៖ ចំាស! ធ្វើមួយថ្ងៃបាន២ហើយអ្នកខ្លះធ្វើមួយថ្ងៃបាន៣ ៤ហ្នឹងគេធ្វើរហាសហ៎ា។

ក៖ ចំាស!

ខ៖ គេឡើងកូតពីយប់ពីអីចឹងទៅ គេចឹងគេឡើងកូតគេហូតអីគេហើយអស់ហើយហ្នឹងគេចាប់ធ្វើរហូ តម៉ង។

ក៖ ចំាស!

ខ៖ គេមានគ្នា បើខ្ញុំមួយថ្ងៃបានតែ២ទេ។

ក៖ កាលពេលហ្នឹងបងអាយុប៉ុន្មានបានបងធ្វើកន្ទេលហ្នឹង?

ខ៖ ហ៊ុំអាយុទើបតែ១៣ឆ្នាំអីហ្នឹង។

ក៖ ហ៊ុ! ធ្វើមួយថ្ងៃបាន២ខ្លាំងហើយ១៣ឆ្នាំ។

ខ៖ ១៣ឆ្នាំ។

ក៖ ហើយមូលហេតុម៉េចបានបោះបង់អាជីពមួយហ្នឹងចោលចឹង?

ខ៖ ហ៊ុ! ចុះបើខ្ញុំពិបាកពេកខ្ញុំដើរមកនៅជាមួយគេ ដើរស៊ីឈ្នួលច្រូតស្រូវច្រូតអីទៅ។

ក៖ ក្រាន់បើជាងហ៎?

ខ៖ ចាស!

ក៖ ព្រោះកន្លែងហ្នឹងលក់អត់សូវបានថ្លៃអីណាអី?

ខ៖ អត់សូវបានថ្លៃផង។

ក៖ ចាស!

ខ៖ ហើយណាមួយយើងក្រអាស្លីករំចេកហ្នឹងទៀត។

ក៖ ហ្អ៎!

ខ៖ ក្រ ដូចថាយើងកាប់មួយសារចឹងគ្មានម្រាំតែលាស់បានបានអីនឹងកាប់ទៀត មានតែទំនេរ។

ក៖ ចុះឥលូវសម្បូរដើមរំចេកអត់នៅស្រុកហ្នឹង?

ខ៖ ឥឡូវអត់មានទេ អស់ហើយ។

ក៖ ចាស!

ខ៖ អត់មានទេឥឡូវ។

ក៖ ហើយតាំងពីបែកពីភូមិស្រុកហ្នឹងមកដែលធ្លាប់ទៅលេងអីអត់?

ខ៖ ធ្លាប់ទៅដែរ។

ក៖ ជាមួយប្តីជាមួយកូនចឹងទៅ?

ខ៖ ចាស! ទៅជាមួយប្តីជាមួយកូន មួយឆ្នាំទៅម្តង។

ក៖ ហ្អ៎ភាគច្រើន ច្រើនទៅតែខែបុណ្យទានហ៎បង?

ខ៖ ចាស ទៅចូលឆ្នាំ ភ្ជុំ។

ក៖ ចាស! ចឹងបងសម្រាប់ជីវិតរបស់បងសម្រាប់ពេលពីនៅពីក្មេងហើយនឹងឥឡូវមានផ្លាស់ប្តូរអីច្រើនអត់?

ខ៖ ហ៊ីដូចគ្នានផ្លាស់ប្តូរអីផង។

ក៖ ដូចនៅតែដដែលហ៎?

ខ៖ នៅតែដដែល។

ក៖ ពីមុនហើយឥឡូវមួយណាសប្បាយចិត្តជាង មួយណាស្រួលជាង?

ខ៖ កាលពីនៅដូចថាសប្បាយហ៎បងអត់ដែលដល់ពេលយើងមានកូនមានអីយើងចេះតែកើតទុកហ្នឹង មិនដឹង បានលុយឯណាឱ្យកូនរៀនសូត្រចឹងទៅណា។

ក៖ ចាសវាពិបាកចឹង ចាស។

ខ៖គិតមួយថ្ងៃៗចង់បែកក្បាលហើយ។

ក៖ ហ្នឹងហើយ ចឹងទ្រាំតិចទៀតទៅ តែបន្តិចទៀតហ្នឹងកូនធំទៅ។

ខ៖ ចាស!

កះ គ្រាន់បើហើយ។

ខះ ប្តីជួយរកចេះតែបានសល់តិចៗតួចទៅហ៎ាបងហ៎ា។

កះ ចំាស!

ខះ បើយើងរកតែយើងពិបាក ឧទាហរណ៍ថាទៅរោងបាន១០,០០០មក ព្រឹកមិញគ្រាន់តែបាន ១០,០០០ មកគ្រាន់តែបង់ សាលាកូនអស់បានហើយមានអីទៀត ហើយកូនមួយថ្ងៃ១០០០។

កះ ចំាស! ២នាក់ប្តីងមួយថ្ងៃ ១០,០០០ជាងហើយនៅម្ហូបស៊ី១០,០០០ទៀតបងឯងគិតមើល។

កះ ប្តីងហើយ។

ខះ អើខ្ញុំគិតមួយថ្ងៃៗចង់បែក។

កះ ដោយសារពូគាត់ឈឺអត់បានជួយរក។

ខះ ចំាស!

កះ គ្រាន់បានធ្វើស្អៅពូណោះ?

ខះ
កាលមុនគាត់បានជួយធ្វើការសំណង់ទៅចេះតែបានទប់ទល់ៗទៅបងហ៎ាតែដល់តលូវអត់ទេវេទនាណាស់។

កះ ចឹងដល់ពេលខ្វះខាតធ្វើម៉េចទៅចឹង? ចេះតែបានទៅរកដែរ?

ខះ ចេះតែបានទៅរកទៅ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹកចឹងទៅ ។

(ស្វាមីរបស់បងស្រី)៖ អញ្ចេក គេចេះតែហៅចេះតែបានតេកតក់ៗចឹងទៅណា។

កះ ហ្ន៎ប្តីងហើយ។ ចឹងសម្រាប់ចូលដល់ចំណង់ចំណូលចិត្តបងស្រីវិញម្តង តើបងចូលចិត្តពិសារម្ហូបអីគេដែរ?

ខះ ស្ងោរហ៎ា!

កះ ម្ហូបពិសេសជាងគេម៉ងហ៎ា?

ខះ អើមិនដឹងម្ហូបអីគេទេខ្ញុំ។

កះ អត់ចាំទេហ៎?

ខះ ចំាស! ចូលចិត្តតែទាំងអស់។

កះ ២នាក់ប្តីប្រពន្ធដូចគ្នាគឺថាម្ហូបអីក៏ញ៉ាំបានដែរ។

ខះ ចំាសៗ! អត់រើសទេ។

(ស្វាមីរបស់បងស្រី)៖ ប្រហុកក៏ហូប ថាមានល្ងលីងល្ងឱ្យហូបក៏ឱ្យហូបដែរល្ង។

ខះ អត់មានរើសទេ ម្ហូបអីក៏ខ្ញុំហូបដែរ តែទឹកត្រីជាមួយនេះក៏ហូបកើតដែរ។

កះ ឱ្យតែមានបាយបងណោះ?

ខះ ចំាសប្តីងហើយ។

ក៖ ចឹងម្ហូបដែលបងចូលចិត្តម្ហូបទាំងអស់ហ្នឹងតើចេះធ្វើម្ហូបទាំងអស់ហ្នឹងអត់?

ខ៖ ចេះតើ។

ក៖ ហើយរៀនពីអ្នកណាគេមកវិញការហូបទាំងអស់?

ខ៖ ខ្ញុំដើរតាមចុងភៅមើលគេចឹងទៅ។

ក៖ ហ្អ៎! ចេះម្ហូបឆ្ងាញ់ៗច្រើនណាស់ចឹង។ចឹងបងដែលចេះលេងឧបករណ៍ភ្លេងអីអត់?

ខ៖ ហ្អ៎! អត់ដែលចេះទេ។

ក៖ អត់ទេហ៎?

ខ៖ ចាំស!

ក៖ ចឹងសម្រាប់ចម្រៀងចូលចិត្តស្តាប់ចម្រៀងអត់?

ខ៖ ចូលចិត្តដែរ។

ក៖អ្នកណាគេសំលេងអ្នកណាគេចូលចិត្តស្តាប់បង?

ខ៖ ចូលចិត្តជាងគេអាខេម។

ក៖ ស្មានតែសុិន សុីសាមុកអី ខេម ។

ខ៖ ចូលចិត្តខេម។

ក៖ សម្លេងស្អកៗ។

ខ៖ ចាំស!

ក៖ បទអីគេពិសេសជាងគេបង?

ខ៖ បទអាស្អី!

ក៖ ទឹកភ្នែកក្មេងពាលអី?

ខ៖ បទស្អី ប្រពន្ធធ្វើការពេលយប់ហ្ន៎។

ក៖ អីគេប្រពន្ធធ្វើការពេលយប់។

ខ៖ ចូលចិត្តស្តាប់ជាងគេអាហ្នឹងខ្ញុំ។

(ស្វាមីរបស់បងស្រី)៖ ជីវិតស្រីឡង់សេហ្នឹង។

ក៖ ប្រហែលហ្នឹងហើយចឹងហ៎។ ចាំ! ចឹងតើដូចជាផ្ទះដែលបងរស់នៅសព្វថ្ងៃផ្ទះរបៀបម៉េចដែរ?ផ្ទះឈើឬ ក៏ ម៉េចដែរ?

ខ៖ ផ្ទះឈើបង ផ្ទះឈើប៉ុន្តែប្រក់សង្កសីហើយជញ្ជាំងក៏សង្កសីដែរ។

ក៖ ចាំស! ហ្នឹងហើយ ចឹងសម្រាប់ជីវិតរបស់បងពេលណាដែរដែលបងគិតថាពិបាកជាងគេនៅក្នុងជីវិត?

ខ៖ រាល់ថ្ងៃពិបាកហើយខ្ញុំរាល់ថ្ងៃ។

ក៖ ហ្នឹងហើយ ដោយសារជីវភាពហ្នឹងហ៎?

ខ៖ ចំាស! ជីវភាពហ្នឹង។

ក៖ ពីក្មេងមករាងស្រួលវិញហ៎?

ខ៖ ចំាស! ពីក្មេងមកយើងអត់ទាន់មានកូនមានអីចឹងយើងចេះតែសប្បាយបងម្នាក់ឯង ថាដល់ពេល យើងមាន កូនយើងគិត យើងគិតថាមានពេលព្រលឹមឡើងកូនទៅរៀនមានលុយមកពីណា ឯណាឯណីចឹង ចេះតែគិតហើយ។

ក៖ ចំាស!

ខ៖ តែកាលយើងនៅម្នាក់ឯងយើងអត់មានគិតអីគេទេ។

ក៖ ដឹងតែមានលុយមានអីបន្តិចបន្តួចអីទៅគ្រាន់ហើយ?

ខ៖ ចំាស! តែដល់ពេលមានកូនគិតកូន។

ក៖ ចំាសហ្នឹងហើយ ចឹងបងតើដូចជាសម្រាប់ជីវិតរបស់បង បងកើតទាន់ដំនាន់ ប៉ុល ពតមែនទេបង?

ខ៖ ចំាស!

ក៖ ចឹងបងមានដូចជាចាំអីគេខ្លះពីដំនាន់ប៉ុល ពត ខ្លះបងអាចរៀបរាប់អោយក្បោះក្បាយអ្វីដែលបងចាំចឹងហ៎?

ខ៖ ខ្លាំភ្លេចអស់ហើយ។

ក៖ ម៉េចចឹង? ភ្លេចអីស្រួលម្ល៉េះ?

ខ៖ ចំាសភ្លេចអស់ហើយ យូរហើយ។

ក៖ ចុះពេលដំនាន់ ប៉ុល ពតហ្នឹងអាយុប្រហែលជាប៉ុន្មានវិញ?

ខ៖ នៅតូចដែរ។

ក៖ ចំាស!

(ស្វាមីរបស់បងស្រី)៖ ៤៥ឆ្នាំហ្នឹងកាលហ្នឹង។

ក៖ ហើយពេលហ្នឹងគេមើលឬក៏ម៉េចដែរ? គេមើលបងឬក៏ម៉េចដែរ?

ខ៖ អ៊ុខ្លាំគាត់អ្នកមើល។

ក៖ ហើយគាត់អត់ទៅធ្វើការទេហ៎បានគាត់មើលចឹង?

ខ៖ គាត់អត់ផង ស្រុកស្រែគាត់អត់មានធ្វើការអីផង។

ក៖ ដូចទៅធ្វើស្រែធ្វើអីហ្ន៎?

ខ៖ អត់ទេ! គាត់នៅមើល កូនៗគាត់ទៅស្លូងទៅដកចឹងទៅ។

ក៖ ហើយម៉េចដែរ អាពត កន្លែងដែលបងរស់នៅស្រួលឬក៏ម៉េច?

ខ៖ ពិបាកអត់មានស្រួលទេ ដូចថាពេលគេបបរឆ្អិនគេរែងចឹង យើងដើរទៅយកបបរទៅ ដើរទៅទាន់គេបាន ហូបទៅ អត់ទាន់អត់ទៅ កូនចានចង្អឹះមួយប៉ុណ្ណឹងគេចែកដើរទៅតាសៗហ្នឹង។

(ស្វាមីរបស់បងស្រី)៖ អំបិលមួយកូនចានបបរ។

ខ៖ ចែកគ្នា។

ក៖ ហើយមួយថ្ងៃបានប៉ុន្មានដងដែរ?

ខ៖ មួយថ្ងៃបានតែ២ដងទេ។

ក៖ ហើយចុះម្តងទៀតញុំអីគេទៅ?

ខ៖ ពេលព្រឹកហើយល្ងាច។

ក៖ ហើយថ្ងៃ?

ខ៖ ថ្ងៃអត់ទេ។

ក៖ ហើយចឹងបានកម្លាំងឯណាទៅបង?

ខ៖ អត់កម្លាំងដែរហ្នឹង។

ក៖ ចុះបើសិនជាខុសពីការគេហៅញុំអីទាំងអស់ហ្នឹងតើបងធ្វើអីគេវិញទៀត?ញុំមានអីគេញុំផ្សេងទៀតទេ?

ខ៖ ខ្ញុំអត់មានអីញុំផង។

ក៖ ងាប់ហើយចឹងពោះហ្នឹងមិនលាន់សម្លេងដល់ការហើយ។

ខ៖ អត់មានលាន់ទេ។

ក៖ មានដំឡងមានអីគេអត់នេះម៉ងហៅ? អូខ! ចឹងបងតើការហូបចុករបស់បងគឺវាពិបាកចឹងម៉ង?

ខ៖ ចាំសវាពិបាកចឹងម៉ង។

ក៖ អូខ! ចឹងបងមានបទពិសោធន៍អីគេខ្លះដែលល្អក្នុងជីវិតដែលបងចង់និយាយចឹងហ៎ា?

ខ៖ មិនដឹងមានស្អីនិយាយ។

ក៖ ចង់ចែកចាយចឹងហ៎ា?

ខ៖ ខ្ញុំអត់ចេះនិយាយទេ។

ក៖ អត់អីទេចឹង អូខេ ឥឡូវបងរៀបការហើយមែនទេ?

ខ៖ ចាំស!

ក៖ មានកូនស្រីប្រុសប៉ុន្មាននាក់?

ខ៖ ស្រីមួយប្រុសមួយ ស្រីបង។

ក៖ ស្រីបងហៅ?

ខ៖ ចាសនេះប្អូន។

ក៖ ចុះនេះពៅទេចុះ?

ខ៖ ចាស!

ក៖ ចំធំហើយចឹង។

ខ៖ ចាស!

ក៖ ចុះកូនស្រីអាយុប៉ុន្មានហើយចឹង?

ខ៖ អាយុ១៨ហើយ។

ក៖ ហ្អ៎! ចឹងបានជួយធ្វើការហើយចឹង?

ខ៖ នៅរៀន ជាប់រៀនអត់បានអត់បានធ្វើការទេ។

ក៖ ឥឡូវគាត់ថ្នាក់ទីប៉ុន្មានហើយ?

ខ៖ ទី១២។

ក៖ ហ្អ៎! ចឹងល្អហើយចឹងបានកូនស្រីធំរៀនដល់ថ្នាក់ទី១២ហើយហ្នឹង។

(ស្វាមីរបស់បងស្រី)៖ ហើយយើងរៀនកំព្យូទ័រអត់អស់លុយទៀតយើងរៀននៅអង្គការ។

ខ៖ អង្គការគេជួយយើងហ៎ា។

(ស្វាមីរបស់បងស្រី)៖ អាហ្នឹងយើងបញ្ជាក់ពីភូមិសង្កាត់ទៅ សំបុត្រ យកទៅគេឱ្យរៀនបើយើងអត់អាហ្នឹង គេអត់ ឱ្យរៀនទេ។

ខ៖ សៀវភៅក្រីក្រ។

ក៖ ហ្នឹងហើយ ចឹងតើកូនបងឈ្មោះអីកូនពៅឈ្មោះអីគេដែរបង?

ខ៖ ហេង រស្មី។

ក៖ ចុះកូនពៅ?

ខ៖ ហេង លីញហ័រ។

ក៖ ហ្នឹងហើយ ហេង លីញហ័រនៅក្នុងសៀវភៅគ្រួសារ។ ចឹងថ្ងៃខែឆ្នាំកំណើតរបស់កូនស្រី ឈ្មោះហេង រស្មី ចឹង គាត់កើតនៅថ្ងៃទី២៤ខែ០៤ឆ្នាំ១៩៩៧ពូណោះ?

(ស្វាមីរបស់បងស្រី)៖ ហ្នឹងហើយ។

ក៖ ហើយកូនប្រុសឈ្មោះ ហេង លីញហ័រ គាត់កើតនៅក្នុងថ្ងៃទី៨ខែ០២ឆ្នាំ២០០៥។ ចាស!

ខ៖ ហ្នឹងហើយ។

ក៖ ហ្អ៎! កូនរុងរើលដែរបង។ចឹងមានតែ២នាក់ហ្នឹងទេ ?

ខ៖ មានតែ២នាក់ហ្នឹង។

ក៖ ហើយមានគម្រោងការថាថ្ងៃអនាគតចង់មានកូនថែមទៀតអីអត់?

ខ៖ ហ៊ឺ! មិនចង់ទេលោកអើយ រកតែ២ហ្នឹងរកមិនចង់បានចិញ្ចឹមគ្នាមិនរស់ផងទៅរកឯណាទៀតលោក។

ក៖ ចឹងបងមានបានអោយកូនទាំង២នាក់អោយទៅសិក្សាទាំងអស់គ្នា?

ខ៖ ចាស! បានទាំង២នាក់ហ្នឹងទៅរៀន អាប្អូនថ្នាក់ទី៦ហើយ ។

ក៖ ចាស! ហើយចុះបងថ្នាក់ទី១២?

ខ៖ ចា!

ក៖ ចឹងបងមូលហេតុអីដែលបងឱ្យកូនទៅរៀនបងចង់ឱ្យគាត់ម៉េចដែរ?

ខ៖ ចង់ឱ្យចេះ ។

ក៖ ក្រៅពីចេះមានអីគេទៀតទេ?

ខ៖ ចង់ឱ្យដល់ពេលដែលធំឡើងទៅធ្វើការធ្វើអីចឹងទៅណា ចិញ្ចឹមយើងម្តងទៅ។

ក៖ កុំឱ្យតែម៉ែចិញ្ចឹមពេកហ៎?

ខ៖ ចាស!

ក៖ ចាសហ្នឹងហើយ។ ចឹងបងដែលពេលបងនៅពីក្មេងហ៎ា បងមានបំណងប្រាថ្នាថាចង់ធ្វើអីអត់?

ខ៖ អត់មានផង។

ក៖ ដែលគិតថាចង់ធ្វើក្រូពេទ្យធ្វើគ្រូបង្រៀនឬក៏អីផ្សេងពីហ្នឹងអត់?

ខ៖ កាលពីតូចញ៉ាំមគិតតែថាហ៊ីមានម៉ែឪនឹងគេអ្នកមានទៅស្រួលចិត្តបន្តិចទៅណា។

ក៖ ចាស!

ខ៖ តែបើថាបំណងធ្វើអីអត់ដែលទេ ចង់ឱ្យតែជួបម៉ែឪមានដូចគេចឹងទៅ។

ក៖ ចាសហ្នឹងហើយ។ ចឹងបងសម្រាប់បងគម្រោងការទៅថ្ងៃអនាគតតើបងត្រូវធ្វើម៉េចដើម្បីក្រុមគ្រួសាររបស់ ទៅ? គ្រាន់តែធ្វើការ ឬក៏មានផែនការអីអីអត់?

ខ៖ ហ៊ឺ! មិនដឹងមានផែនការអីទេនេះ។

ក៖ ចេះតែរស់ពីមួយថ្ងៃទៅមួយថ្ងៃចឹងទៅ?

ខ៖ ចាស! រកមួយថ្ងៃរស់មួយថ្ងៃទៅខ្ញុំ និយាយត្រង់ម៉ងអត់លាក់ទេ។ ធ្វើស្អី។

ក៖ ចាស!

ខ៖ កំពុងថាបើ ខ្ញុំឈឺមិនដឹងថាកូនហ្នឹងបានលុយឯណារៀនសូត្រទេ ដាច់ខ្យល់ងាប់ហើយ។

ក៖ ចឹងកុំឈឺ។ ចឹងបងមួយនេះគឺជាសំណួរមួយចុងក្រោយចឹងហ៎ា។ តើបងមានអីដែលចង់ផ្តែផ្តាំទៅកាន់កូនចៅ ជំនាន់ក្រោយដូចជាឱ្យគាត់ដើរលើផ្លូវម៉េចដែរ ហើយឱ្យគាត់ ប្រាប់គាត់ ឱ្យដឹងពីបងទៀតដែរ បងមានអីចង់ប្រាប់ បងអាចប្រាប់ទាំងអស់មកក៏បានយូរប៉ុន្មានក៏អត់ អីដែរ?

ខ៖ មិនដឹងមានអីផ្តាំមានតែសូមឱ្យដើរតែផ្លូវល្អ។

ក៖ ចាំស! ហើយឱ្យគាត់ជៀសផុតពីផ្លូវអីគេដែរបង?

ខ៖ ឱ្យជៀសផុតពីអាជក់ថ្នាំញៀន ជក់អីណាបង។

ក៖ ចាំស! ហើយមានអីគេទៀតចង់ប្រាប់គាត់ថែមទៀតទេ?

ខ៖ អត់មានអីទៀតទេមានតែប៉ុណ្ណឹង។

ក៖ ហើយចឹងសម្រាប់ថ្ងៃហ្នឹងខ្ញុំអរគុណច្រើនមែនទែនហើយចឹងអ្វីទាំងអស់ហ្នឹងសម្លេងរបស់បងគឺពួកយើង នឹងត្រូវបានរក្សាទុកហើយទុកអោយកូនចៅរបស់បងជំនាន់ក្រោយគាត់បានស្តាប់ពីជីវិតរបស់បងថាបងជួបទុក្ខ លំបាកអីគេខ្លះ។ហើយមានអីចង់បន្ថែមទៀតអីអត់?

ខ៖ អត់មានទេ។

ក៖ ចឹងមានតែប៉ុណ្ណឹងទេចឹងហ្នឹ។

ខ៖ ចាំស!

ក៖ ចាំស! ចឹងអរគុណច្រើន។